# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៦៥

## ស្តីពី

## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដោយមានការឯកភាព ពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋមរបស់ក្រសួងសុខាភិបាល ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ

**គ** ដូចមានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា ២.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ស្ថិតនៅក្រោមឱវាទក្រសួងសុខាភិបាល ប្រមូលផ្តុំមន្ត្រីបច្ចេកទេសសុខាភិបាលកំរិតបឋម បំរើការងារក្នុងវិស័យសុខាភិបាល តាមអង្គភាពជំនាញថ្នាក់កណ្តាល និងខេត្ត ក្រុង និងគ្រឹះស្ថានសាធារណៈរបស់ក្រសួង ស្ថាប័នរដ្ឋ។

**មាត្រា ៣.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម មានមុខងារក្នុងការប្រតិបត្តិបច្ចេកទេសជំនាញ សុខាភិបាល។

## ជំពូកទី ២

## ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម មាន ៣ ឋានន្តរស័ក្តិ ៖

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលបឋម ដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលបឋម ដើមខ្សែ មាន ១០ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលបឋម មាន ១៤ ថ្នាក់។

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៥.-**

ការជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត និងឬ ជាមន្ត្រីរាជការ។ ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជនជាសិស្ស និស្សិត និងជាមន្ត្រីរាជការតាមផ្នែកនីមួយៗ ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសុខាភិបាល។

**មាត្រា ៦.-**

ការប្រលងជ្រើសរើសចូលក្របខ័ណ្ឌ ក្នុងចំណោមនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំគិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រផ្នែកណាមួយយ៉ាងទាប ដូចខាងក្រោម ៖

- សញ្ញាប័ត្រគិលានុបដ្ឋាក គិលានុបដ្ឋាយិកាបឋម
- សញ្ញាប័ត្រឆ្មបបឋម
- សញ្ញាប័ត្រអ្នកបច្ចេកទេសមន្ទីរពិសោធន៍បឋម

  និងសញ្ញាប័ត្រជំនាញ ផ្នែកបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្រឯទៀត ដែលមានតំលៃស្មើនឹងសញ្ញាប័ត្រខាងលើ ។

ចំពោះមន្ត្រីដែលមានសញ្ញាប័ត្រដូចខាងលើ អាចប្រលងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌនៃឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៣៥ ឆ្នាំ។

## ជំពូកទី ៤

## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.-**

បេក្ខជន ដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ត្រូវទទួលការបណ្តុះបណ្តាលដំបូង រៀបចំឡើងដោយក្រសួងសុខាភិបាល ហើយមានឋានៈជានិស្សិតមន្ត្រីសុខាភិបាលបឋម។

**មាត្រា ៨.-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីសុខាភិបាលបឋម ត្រូវចាត់អោយទៅបំរើការងារនៅតាមអង្គភាពសុខាភិបាលខេត្ត ក្រុង និងថ្នាក់កណ្តាល ដោយផ្អែកលើលទ្ធផលនៃការបណ្តុះបណ្តាល ហើយត្រូវតែងតាំងជាមន្ត្រីសុខាភិបាលបឋមកម្មសិក្សា ដោយប្រកាសរបស់ក្រសួងសុខាភិបាល។

មន្ត្រីសុខាភិបាលបឋម ដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល១២ ខែ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣។

មន្ត្រីសុខាភិបាលបឋម ដែលជ្រើសរើសចេញពីមន្ត្រីរាជការ ត្រូវធ្វើកម្មសិក្សាសាកល្បងរយៈពេល ០៦ ខែ។

មន្ត្រីសុខាភិបាលបឋមដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិ ទី៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ លើបន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន។

មន្ត្រីសុខាភិបាលបឋម ដែលធ្វើកម្មសិក្សាមិនបានសំរេចជោគជ័យ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅលើកទី២ ទៀត។ ក្នុងករណីមិនទទួលជោគជ័យជាលើកទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីសិស្ស និស្សិត ត្រូវលុបឈ្មោះចេញ កម្មសិក្សាការីដែលជ្រើសរើសពីមន្ត្រីរាជការ ត្រូវបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេលបណ្តុះបណ្តាលដំបូង និងកម្មសិក្សា សំរាប់អតីតភាពការងារ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសុខាភិបាល។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ៩.-**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដូចមានកំណត់ក្នុងមាត្រា៣ ខាងលើ។

## ជំពូកទី ៦

## ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១០-**

មន្ត្រីសុខាភិបាលបឋម អាចត្រូវដាក់ឱ្យស្ថិតក្រៅក្របខ័ណ្ឌដើម ឬ ក្រៅតំណែងដើម ដើម្បីទៅបំរើការងារនៅតាមក្រសួង ស្ថាប័ន ឬអង្គភាពផ្សេងណាមួយ តាមតំរូវការ និងតាមការយល់ព្រមពីសាមីជន។

## ជំពូកទី ៧
## ការដំឡើងថ្នាក់ និង ការដំឡើងឋានន្តរស័ក្តិ

**មាត្រា ១១ .-**

មន្ត្រីសុខាភិបាលបឋម ត្រូវដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

លក្ខណៈសម្បត្តិ ជាមូលដ្ឋានសំរាប់ការពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោម៖

- គំនិតផ្តួចផ្តើមច្នៃប្រឌិត និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវ វិន័យការងារ មនសិការវិជ្ជាជីវៈ
- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- សាមគ្គីធម៌ និង សីលធម៌រស់នៅ។

ការដំឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព។

**មាត្រា ១២ .-**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតាត្រូវដំឡើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ចំនួនតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចខាងក្រោម ៖

- ៥% ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី១
- ២៥% ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី២
- ៧០% ឡើងទៅ សំរាប់ឋានន្តរស័ក្តិទី៣។

ការដំឡើងឋានន្តរស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិ និងការវាយតំលៃរបស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាលបន្តនៅក្នុង ឬក្រៅប្រទេស។

ការដំឡើងថ្នាក់ និង ការដំឡើងឋានន្តរស័ក្តិនៃមន្ត្រីសុខាភិបាលបឋម ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល។

**មាត្រា ១៣ .-**

សន្ទស្សន៍ សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតំលៃឯកតានៃសន្ទស្សន៍ ត្រូវបានកំណត់ស្រប តាមមាត្រា ៣ និងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំរបស់មន្ត្រីរាជការ។

## ជំពូកទី ៨
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៤ .-**

មន្ត្រីសុខាភិបាលបឋម ដែលក្រសួងចាត់ឱ្យទៅទទួលការបំប៉ន ឬការបណ្តុះបណ្តាលបន្តរយៈពេលសរុបយ៉ាងតិច ០៦ ខែ ក្នុងជំនាញរបស់ខ្លួន ដោយមានវិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ការសិក្សា ត្រូវទទួលការតំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ តាមវេនជ្រើសរើស ។

**មាត្រា ១៥ .-**

មន្ត្រីសុខាភិបាលបឋម ត្រូវដាក់ឱ្យចូលនិវត្តន៍ ពេលដល់អាយុ ៥៨ ឆ្នាំ ។

ការដាក់ឱ្យចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខងារ និង មុខតំណែងពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងវិស័យសុខាភិបាលនៅរដ្ឋបាលកណ្តាល និង ខេត្តក្រុង របស់ក្រសួងស្ថាប័នរដ្ឋ ហើយដែលមានសញ្ញាប័ត្រណាមួយ ដូចមានចែងក្នុងមាត្រា៦ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៧.-**

មន្ត្រីសុខាភិបាលបឋម ដែលបានតែងតាំងរួចហើយក្នុងមុខតំណែងគ្រប់គ្រងណាមួយ ត្រូវអនុញ្ញាតឱ្យបន្តមុខតំណែងរបស់ខ្លួន លើកលែងតែមានការចាំបាច់ត្រូវផ្លាស់ប្តូរមុខតំណែង ដែលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជ្យក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ២០.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ពរល.០២.០៦.០០១៧៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ១៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**ឈាងី តាន់**